៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ប្រកាសលេខ២១៧ ប្រក.ដ.ន.ស. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់ឆ្នេរសមុទ្រក្រុងកែប ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៥ ដែលក្នុងនោះមាន តំបន់រណបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥ តំបន់បន្ទាប់ពីតំបន់រណបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង២,៥ និងតំបន់បន្ទាប់ពីតំបន់នេះទៀតត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,៥។

**៤.២- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍**

- ពង្រឹងមុខងារមជ្ឈមណ្ឌលទីក្រុង ដោយយកចិត្តទុកដាក់លើសកម្មភាពទេសចរណ៍ ពាណិជ្ជកម្ម និងធុរកិច្ច
- អភិវឌ្ឍទេសចរណ៍សម្រាប់ការស្នាក់នៅរយៈពេលយូរ ប្រកបដោយផាសុកភាពតាមរយៈអាហារសមុទ្រស្រស់ៗ ខ្យល់អាកាសល្អបរិសុទ្ធ ទិដ្ឋភាពធម្មជាតិ ភ្នំ និងឧទ្យានជាតិកែបដ៏ស្រស់ស្អាត ជាមួយនឹងសេវាកម្ម ត្រួតពិនិត្យសុខភាព និងការស្តារនីតិសម្បទា ដោយបន្តការសាងសង់សណ្ឋាគារ កម្រិតស្តង់ដារផ្ទះសំណាក់ បឹងហ្គាឡូឱ្យបាន២៥០០ បន្ទប់ នៅឆ្នាំ២០៣០ ជាមួយនឹងភោជនីយដ្ឋាន អាហារដ្ឋាន ដែលប្រកបដោយអនាម័យចំណីអាហារ
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវធនធានតំបន់ឆ្នេរសមុទ្រដ៏សម្បូរបែប និងប្រកបដោយភាពទាក់ទាញ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ គេហទំព័រតំបន់ទេសចរណ៍ បណ្តាញព័ត៌មានសង្គម និងព័ត៌មានវិទ្យា សម្រាប់ប្រកួតប្រជែងជាមួយនឹងទីក្រុងជាប់សមុទ្រនានានៅអាស៊ី ដែលមានទេសចរមកលម្ហែកម្សាន្តច្រើនកុះករ
- បន្តការកែលម្អឆ្នេរខ្សាច់កម្សាន្ត តាមរយៈការចាក់បំពេញខ្សាច់ដែលមានពណ៌សក្បុស ពង្រីក និងបង្កើតបន្ថែមនូវឆ្នេរខ្សាច់សិប្បនិម្មិត បណ្តុះបណ្តាលឆ្នាំសមុទ្រ និងពង្រឹងការការពារលម្ហសមុទ្រ
- អភិវឌ្ឍក្រុងកែប ជាទីក្រុងស្អាតដែលមានសមុទ្រខៀវស្រងាត់ ទីក្រុងបៃតង ប្រកបផាសុកភាព មានការការពារបរិស្ថាន និងការគ្រប់គ្រងអនាម័យ ដើម្បីទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិ
- រៀបចំសេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ចឱ្យឈានដល់កម្រិតស្តង់ដារជាតិ និងអន្តរជាតិ និងបណ្តុះបណ្តាលបុគ្គលិក ព្រមទាំងអ្នកគ្រប់គ្រងសេវាកម្មទេសចរណ៍ ឱ្យទទួលបានជំនាញវិជ្ជាជីវៈច្បាស់លាស់
- រៀបចំសមាគមសណ្ឋាគារ នៅតំបន់ឆ្នេរសមុទ្រ និងផ្សារភ្ជាប់នឹងយុទ្ធនាការសមាគមមួយឃុំមួយផលិតផលមួយ
- វិនិយោគវិស័យទេសចរណ៍ នៅតាមបណ្តាកោះទាំង១៣ ដោយបង្កើតនូវសេវាកម្សាន្តដ៏សម្បូរបែប មានសណ្ឋាគារលំដាប់ផ្កាយ៥ ផ្ទះសំណាក់ បឹងហ្គាឡូ និងសេវាកម្សាន្តជាច្រើនទៀត កសាងកន្ត្រក

យោងជិះពីដីគោកទៅបណ្តាកោះ ឬផ្លូវក្រោមទឹក និងរៀបចំនាវានិងអូប័រទំនើបៗ ប្រកបដោយសុវត្ថិភាព សម្រាប់ភ្ញៀវទេសចរណ៍ បង្កើតកម្មវិធីទេសចរ សិល្បៈ របាំ ប្រពៃណីវប្បធម៌ខ្មែរបុរាណ និងជនជាតិភាគតិចជាដើម។ល។

- បន្តកែលម្អ និងរៀបចំមហាវិថី វិថី អនុវិថី ប្រព័ន្ធចរាចរណ៍ ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ ប្រព័ន្ធការពារសុវត្ថិភាព ផ្លូវសម្រាប់ដឹកជញ្ជូន ផ្លូវសម្រាប់ថ្មើរជើង គន្លងផ្លូវទោចក្រយាន តាមបទដ្ឋានបច្ចេកទេសអភិវឌ្ឍន៍បៃតង ដោយធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ
- កែលម្អ និងរៀបចំផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្តល់សេវាកម្ម និងព័ត៌មានទេសចរណ៍
- ធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍ទេសចរណ៍ទៅក្នុងផែនការអភិវឌ្ឍន៍ទីក្រុង ដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាព
- ការពារ និងអភិរក្សតំបន់អេកូទេសចរណ៍ ធនធានធម្មជាតិ ឆ្នេរកម្សាន្ត និងកោះ ដោយត្រូវកំណត់ដីចំណីឆ្នេរសមុទ្រ តំបន់រណប ព្រៃកោងកាង ស្រែអំបិល តំបន់ការពារទេសភាព និងកសិកម្ម
- ធ្វើសមាហរណកម្មតំបន់រមណីយដ្ឋានទេសចរណ៍រួមមានឆ្នេរសមុទ្រ កោះ ឧទ្យានជាតិ អគារវប្បធម៌ ស្រែអំបិល ចំការម្រេច និងភ្នំសរសៀរ ជាមួយនឹងតំបន់ទេសចរណ៍ក្នុងខេត្តកំពត
- អភិវឌ្ឍនិងអភិរក្សតំបន់ឆ្នេរសមុទ្រ កោះ ប្រជុំកោះ ឧទ្យានសមុទ្រ និងរមណីយដ្ឋានទេសចរណ៍ធម្មជាតិខេត្តកែបជារមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក
- រៀបចំឱ្យមានសារមន្ទីរសមុទ្រ នៅក្រុងកែប
- បង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការកសាងសម្បទាទេសចរណ៍រួមមាន ការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច និងពិព័រណ៍ផលិតផលក្នុងស្រុក
- យកចិត្តទុកដាក់និងពង្រឹងសុវត្ថិភាព ប្រព័ន្ធ ឬមធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេស ត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម សន្តិសុខការពារតាមរមណីយដ្ឋាន ឆ្នេរសមុទ្រ កោះ ព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់
- សុវត្ថិភាពចំណីអាហារក៏ត្រូវតែយកចិត្តទុកដាក់ ដោយត្រូវជំរុញលើកកម្ពស់អនាម័យ ប្រព័ន្ធត្រួតពិនិត្យស្តង់ដា និងបញ្ហាជំងឺឆ្លងផ្សេងៗតាមរយៈចំណីអាហារ
- អភិវឌ្ឍផលិតផលទេសចរណ៍ធម្មជាតិ និងការរៀបចំទេសចរណ៍កែច្នៃ ពិសេសតាមព្រៃកោងកាង និងក្នុងឧទ្យានជាតិកែប
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈខេត្តកែបលើវិស័យទេសចរណ៍
- ពង្រីកឆ្នេរកម្សាន្តនៅចំណុចពយព្រះរាជដំណាក់ ដែលមានបណ្តោយប្រវែង១០០០ ម៉ែត្រ និងទទឹងប្រវែង៥០០ ម៉ែត្រ ដើម្បីបង្កើតជាទីតាំងចំណតរថយន្ត សួនច្បារលម្ហែកម្សាន្ត សួនកុមារ ផ្សាររាត្រី ទីលានសម្រាប់ប្រជាពលរដ្ឋមកពីបណ្តាខេត្តឆ្ងាយៗកម្សាន្ត និងសេវាបម្រើវិស័យទេសចរណ៍ផ្សេងៗទៀត
- កែលម្អផ្លូវព័ទ្ធព័ន្ធជុំវិញទំនប់ប៉ោហេង ដើម្បីបង្កើតបន្ថែមទៀតនូវតំបន់ទេសចរណ៍។

## ៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម

ហេដ្ឋារចនាសម្ព័ន្ធត្រូវតែពង្រឹង និងលើកកម្ពស់ឱ្យដល់កម្រិតសម្រាប់បម្រើវិស័យទេសចរណ៍ សេដ្ឋកិច្ច និងបរិស្ថាននៅក្នុងក្រុងកែប រួមមានៈ

### ៤.៣.១- ផ្លូវថ្នល់

- បន្តការកសាងផ្លូវប្របមាត់សមុទ្រ រហូតទៅតភ្ជាប់ជាមួយនឹងផ្លូវប្របមាត់សមុទ្រខេត្តកំពត ព្រមទាំងបន្តការកែលម្អ និងថែទាំផ្លូវធ្វើឱ្យប្រសើរឡើងនូវបណ្តាញផ្លូវដែលមានស្រាប់ដើម្បីចូលរួមការអភិវឌ្ឍវិស័យទេសចរណ៍ និងការដឹកជញ្ជូន។ ជាមួយគ្នានេះ ក៏ត្រូវបង្កបរិយាកាសវិនិយោគដើម្បីធ្វើការអភិវឌ្ឍតាមបណ្តោយឆ្នេរសមុទ្រនូវគម្រោងកសាងទីក្រុងថ្មីបន្ថែមទៀត
- បន្តរៀបចំផ្លូវឱ្យល្អប្រណីត អមដោយដើមផ្កាអមសងខាងផ្លូវ និងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បរិក្ខាផ្លូវថ្នល់ ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រង និងបង្គោលភ្លើងភ្លឺចម្រុះពណ៌ ប្រកបដោយក្បូរក្បាច់រចនានិងមានរចនាបថទាក់ទិននឹងធម្មជាតិ និងសក្តានុពល ទាក់ទាញទេសចរ និងអ្នកដំណើរឆ្លងកាត់ទីក្រុងនេះ
- សាងសង់ស្ពានរលង និងទំនប់ការពាររលកចំនួន៣ កន្លែងដើម្បីឱ្យទឹកសមុទ្រស្ងប់ គ្មានរលកធំៗមករំខានដល់ភ្ញៀវទេសចរ និងការរៀបចំព្រឹត្តិការណ៍ផ្សេងៗដូចជាៈ ពិធីបុណ្យសមុទ្រវិលជុំ បុណ្យឆ្លងឆ្នាំ បុណ្យប្រពៃណីជាតិ ពិព័រណ៍ពាណិជ្ជកម្ម និងព្រឹត្តិការណ៍សំខាន់ផ្សេងៗទៀត
- កែលម្អផ្លូវវង់តូចប្រវែង៨ គីឡូម៉ែត្រក្នុងឧទ្យានជាតិកែប និងកសាងផ្លូវក្រវ៉ាត់ឧទ្យាន ដើម្បីការពារឧទ្យានជាតិកែប និងបម្រើវិស័យទេសចរណ៍ធម្មជាតិ
- រៀបចំឱ្យមានរង្វង់មូល ផ្លូវកែង ត្រង់ចំណុចរូបសំណាកស្តេចកន (ផ្លូវចេញពីរង្វង់មូលព្រះឥស្វរដៃដប់ ឆ្ពោះទៅកាត់កែងផ្លូវប្របមាត់សមុទ្រ ត្រង់ចំណុចរូបសំណាកស្តេចកន) និងរង្វង់មូលជាច្រើនទៀតតាមផ្លូវប្របមាត់សមុទ្រ
- ផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវគោក។

### ៤.៣.២- ផ្លូវទឹក

- កសាងកំពង់ផែទេសចរណ៍កម្រិតអន្តរជាតិដ៏ស្រស់ស្អាតជាមួយនឹងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ ដោយស្តារ និងជីកឃ្លង ដើម្បីឱ្យទឹកសមុទ្រជ្រៅ ធានាបាននូវនាវាទេសចរណ៍ធំៗអាចចូលចតបាន
- កសាងចំណតទូកនេសាទ ដើម្បីគ្រប់គ្រងការនេសាទផង និងរក្សាសណ្តាប់ធ្នាប់ សោភ័ណភាពរបៀបរៀបរយទូកនេសាទតាមបណ្តោយឆ្នេរសមុទ្រផង។

### ៤.៣.៣- ផ្លូវដែក

- បន្តគ្រប់គ្រង ការពារ និងថែរក្សាផ្លូវដែក ដីចំណីផ្លូវដែក និងដីស្ថានីយអយស្ម័យយាន
- ស្ដារ អភិវឌ្ឍ និងធ្វើទំនើបនីយកម្មស្ថានីយ៍អយស្ម័យយានមួយកន្លែង ស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ
- លើកទឹកចិត្តឱ្យមានការធ្វើដំណើរ និងដឹកជញ្ជូន តាមរថភ្លើង។

### ៤.៣.៤- ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា

- ពង្រីកបន្ថែមបណ្ដាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- បន្ត និងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ
- ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់រថយន្តដើរដោយអាគុយ
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច និងពាណិជ្ជកម្ម។

### ៤.៣.៥- ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌

- ស្ដារ និងរៀបចំលម្ហសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្សគ្រប់វ័យ រួមមាន កុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការ ឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យសម្រាប់ជនពិការ និងបរិក្ខាសម្រាប់ជនពិការនៅតាមទីសាធារណៈ អគារសាធារណៈ និងកន្លែងផ្ដល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈគ្រប់កម្រិត តាមភូមិ សង្កាត់ ក្នុងក្រុងកែប ស្របតាមអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យ ឱសថស្ថាន នៅតាមសង្កាត់ និងក្នុងក្រុង ស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- បង្កើតមជ្ឈមណ្ឌលថែទាំសុខភាព ថែទាំវេជ្ជសាស្ត្រ និងខ្យល់អាកាសធម្មជាតិ។

### ៤.៣.៦- ការផ្គត់ផ្គង់ទឹកស្អាត

- រៀបចំឱ្យមានប្រព័ន្ធទឹកស្អាត ដោយយកចិត្តទុកដាក់លើគុណភាពនិងបរិមាណ
- លើកទឹកចិត្តឱ្យមានការវិនិយោគលើវិស័យទឹកស្អាត ដោយប្រើប្រាស់ប្រភពទឹកនៅទំនប់ប៉ោហេង

- សិក្សាប្រភពទឹកផ្សេងៗ ដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់ក្រុង ដោយចៀសវាងការប្រើប្រាស់ប្រភពទឹកក្រោមដី
- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការផ្សេងៗ ក្នុងការការពារប្រភពផ្គត់ផ្គង់ទឹកបណ្តាលមកពីការអភិវឌ្ឍក្រុង។

**៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក**

- ណែនាំឱ្យប្រជាពលរដ្ឋក្នុងក្រុងធ្វើកសិកម្មសរីរាង្គ ដោយប្រើជីធម្មជាតិសម្រាប់ការប្រើប្រាស់ក្នុងតំបន់ និងនាំចេញ
- អនុវត្តយុទ្ធនាការសហគមន៍មួយ ផលិតផលមួយ
- ពង្រឹង និងពង្រីកធនាគារក្តាម
- ថែរក្សា និងការពារដីស្រែអំបិល ឱ្យមានប្រសិទ្ធភាព និងចីរភាព
- បង្កបរិយាកាសល្អ លើកទឹកចិត្ត និងជំរុញការវិនិយោគក្នុងស្រុក និងក្រៅស្រុកលើវិស័យកសិកម្ម និងវារីវប្បកម្ម ដោយផ្អែកលើធនធានសមុទ្រ ដើម្បីគាំទ្រដល់វិស័យទេសចរណ៍ និងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងក្រុង
- បង្កើនគុណភាពនិងផ្សព្វផ្សាយផលិតផលម្រេច ធុរេន និងទឹកត្នោតឆ្អិន ដែលផលិតដោយកសិករនៅមូលដ្ឋាន ឬអ្នកវិនិយោគក្នុងស្រុក ដើម្បីលក់ជូនភ្ញៀវទេសចរ
- ការពារដីកសិកម្ម និងជំរុញការអភិវឌ្ឍវិស័យកសិកម្មបែបទំនើប
- ពង្រីកការកែច្នៃធនធានសមុទ្រ ដើម្បីលក់ជូនភ្ញៀវទេសចរ។

**៤.៥- យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច**

- ដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដីអតីតកាស៊ីណូ ដីចំណីឆ្នេរសមុទ្រ និងដីចំណីផ្លូវដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ
- យកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋក្រីក្រនិងជនងាយរងគ្រោះ ជាពិសេសប្រជានេសាទដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ
- ជំរុញឱ្យសហគមន៍ទទួលបានការគាំទ្រ និងលើកទឹកចិត្តពីផ្នែកសាធារណៈនិងសង្គមស៊ីវិល
- អភិវឌ្ឍសមត្ថភាពរបស់ប្រជាជននៅជនបទ ឱ្យមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបាន ដើម្បីលើកកម្ពស់កម្រិតជីវភាព។

**៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ**

**៤.៦.១- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង**

- បន្តថែរក្សានិងជំរុញការអភិវឌ្ឍទីតាំងទុកដាក់សំរាមដែលមានផ្ទៃដីទំហំសរុបប្រមាណ១៤ ហិកតា ស្ថិតនៅក្នុងភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ដោយប្រើបច្ចេកវិទ្យានិងប្រព័ន្ធដំណើរការដើម្បីធានាបាននូវ អនាម័យល្អ

- ពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់គ្រប់គ្រងសំណល់រឹង
- រៀបចំមធ្យោបាយ និងបរិក្ខាប្រមូលសំណល់រឹង និងរៀបចំទីតាំងសម្រាប់ស្តុកសំណល់រឹងបណ្តោះអាសន្នស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដារទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹង និងបែងចែកសំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញបាន
- អនុវត្តគោលការណ៍គ្រប់គ្រងសំណល់រឹង តាមរយៈការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ
- ដឹកនាំនិងបំផុសការចូលរួមរបស់ប្រជាពលរដ្ឋ និងការវិនិយោគរបស់វិស័យឯកជន និងសាធារណៈ។

### ៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

- រៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅផ្សារក្តាម ឆ្នេរកែប ឆ្នេរថ្មី តំបន់ក្រោយផ្សារកែប ផ្សារដំណាក់ចង្អើរ និងទីប្រជុំជនផ្សារសេះស ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- រៀបចំ និងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលលូសាធារណៈ
- ណែនាំម្ចាស់សំណង់លំនៅឋាន សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈឱ្យរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យឱ្យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបាននិរន្តរភាពតំបន់ទេសចរណ៍ធម្មជាតិស្ងប់ស្ងាត់ និងស្នាក់នៅរយៈពេលយូរ។

### ៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

ផ្អែកតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងអនុក្រឹត្យលេខ១៣៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ឧទ្យានជាតិកែប ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថានមានដូចខាងក្រោម៖

- តំបន់អាងទឹកអូរក្រសារ និងអាងទឹកប៉ោហេង
- តំបន់ឆ្នេរសមុទ្រ សមុទ្រ ធនធានសមុទ្រ កោះ និងផ្លូវទឹកដែលតភ្ជាប់នឹងសមុទ្រ
- តំបន់ឧទ្យានជាតិកែប
- តំបន់ព្រៃកោងកាង
- តំបន់ស្រែអំបិល
- តំបន់សហគមន៍នេសាទ
- តំបន់កសិកម្ម។

### ៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ត្រូវការពារ និងថែរក្សាតំបន់អាងទឹកអូរក្រសារ និងអាងទឹកប៉ោហេង ដោយត្រូវទប់ស្កាត់ការទន្ទ្រានកាន់កាប់ ការតាំងទីលំនៅ ការកាយដីដែលនាំឱ្យបាក់ទំនប់ ការបំពុលទឹក
- ត្រូវគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ សមុទ្រ ធនធានសមុទ្រ កោះ និងផ្លូវទឹកដែលតភ្ជាប់នឹងសមុទ្រស្របតាមសារាចរណែនាំលេខ០១ ស.រ.ណ.ន. ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានគតិយុត្តជាធរមាន
- ត្រូវការពារ ថែរក្សា និងអភិវឌ្ឍតំបន់ឧទ្យានជាតិកែប ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន
- ត្រូវការពារ ថែរក្សា និងអភិវឌ្ឍតំបន់ព្រៃកោងកាង ដើម្បីជាកន្លែងពងកូន ឬកន្លែងរកចំណីសម្រាប់ធនធានវារិជាត និងប្រភេទត្រី
- កាត់បន្ថយការបំពុលខ្យល់ដោយម៉ាស៊ីន និងមធ្យោបាយដឹកជញ្ជូនតាមរយៈការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ
- ត្រូវរក្សាផ្ទៃដីស្រែអំបិល ដោយចៀសវាងការប្តូរប្រភេទនៃការប្រើប្រាស់ដី ឬមុខងារប្រើប្រាស់ដី ដើម្បីថែរក្សាទិន្នផលអំបិល អត្តសញ្ញាណ និងសក្តានុពលរបស់ក្រុង និងខេត្តកែប
- ពង្រឹងសមត្ថភាពសហគមន៍នេសាទក្នុងការធ្វើនេសាទ ការពារដែននេសាទ និងគ្រប់គ្រងធនធានសមុទ្រប្រកបដោយចីរភាព
- ការពារផ្ទៃដីកសិកម្មដោយចៀសវាងការប្តូរប្រភេទនៃការប្រើប្រាស់ដី និងលើកទឹកចិត្តការប្រើប្រាស់ដីសរីរាង្គ
- បោះបង្គោលព្រំប្រទល់ដីចំណីឆ្នេរសមុទ្រឱ្យបានច្បាស់លាស់ ដើម្បីខណ្ឌចែកឱ្យដាច់រវាងដីរដ្ឋនិងដីឯកជន
- ដោះស្រាយវិវាទដីធ្លី និងវិវាទនៃការប្រើប្រាស់ដី ស្របតាមយន្តការ និងបទដ្ឋានគតិយុត្តជាធរមាន
- អនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងការសាងសង់នៃគម្រោងអភិវឌ្ឍន៍និងវិនិយោគនានា
- ផ្សព្វផ្សាយឯកសារគតិយុត្តពាក់ព័ន្ធការងាររៀបចំដែនដីនិងនគរូបនីយកម្ម និងការងារគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

## ៤.៧- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

- រៀបចំបណ្តាញលូរំដោះទឹក បន្តការដាំដើមឈើតាមបណ្តោយឆ្នេរដែលធននឹងទឹកប្រៃ រៀបចំជើងទេរនៃឆ្នេរសមុទ្រ និងកសាងទំនប់ការពាររលកចំនួន៣ កន្លែង ដើម្បីការពាររលកធំៗ និងការហូរច្រោះ ឬភាពសឹករិចរិលនៃឆ្នេរសមុទ្រ

- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពកាយយកដីភ្នំ និងការកាប់ទន្រ្ទានព្រៃក្នុងឧទ្យានជាតិកែប ភ្នំ និងកសាងជញ្ជាំងទប់ភ្នំ ដើម្បីចៀសវាងកុំឱ្យរអិលបាក់ដីភ្នំ
- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពបូមយកដីនៅក្នុងបាតសមុទ្រដែលមិនសមស្របតាមបទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន
- រាល់គម្រោងអភិវឌ្ឍន៍តាមបណ្តោយឆ្នេរសមុទ្រ និងកោះចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពង្រឹងយន្តការ និងមធ្យោបាយសម្រាប់បង្ការ ទប់ស្កាត់ និងប្រឆាំងភ្លើងឆេះព្រៃនៅក្នុងឧទ្យានជាតិ ភ្នំ និងនៅលើកោះ
- លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រក្រុងកែប ដោយសិក្សានិងរៀបចំផែនការប្រើប្រាស់ដី ឱ្យបានគ្រប់ជ្រុងជ្រោយ
- អនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

### ៤.៨- យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន

ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន គឺជាកត្តាសំខាន់ចាំបាច់ និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍន៍ក្រុង និងបរិស្ថាន។ ដូច្នេះ ចាំបាច់ត្រូវ៖

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្ត និងគម្រោងដែលត្រូវស្នើឡើងក្នុងក្រុង និងខេត្ត
- បណ្តុះបណ្តាលធនធានមនុស្សទាំងនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ពិសេសការគ្រប់គ្រង អភិវឌ្ឍន៍ និងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- អនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋាន តាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀត ដល់រដ្ឋបាលមូលដ្ឋាន សម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេសសម្រាប់ការជួសជុលនិងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការលើកកម្ពស់សោភ័ណភាព និងបរិស្ថានទីក្រុង។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងប្លង់គោលប្រើប្រាស់ដីក្រុងកែប រដ្ឋបាលក្រុងកែប និងខេត្តកែប និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗ ដូចតទៅ៖

### ៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម

តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប និងខេត្តកែប បទប្បញ្ញត្តិនគរូបនីយកម្មដែលត្រូវរៀបចំ រួមមាន៖

- ផែនទីកំណត់កម្ពស់អគារក្នុងក្រុង ជាពិសេសនៅតាមបណ្តោយឆ្នេរសមុទ្រ និងនៅលើកោះ
- ផែនទីកំណត់ទីតាំងលម្ហសាធារណៈ ផ្ទៃបៃតង ផ្លូវថ្នល់ ផ្លូវនិងស្ថានីយអយស្មយយាន កំពង់ផែ ទំនប់ទឹក ប្រឡាយទឹក ដីចំណីឆ្នេរសមុទ្រ។ល។
- ផែនទីកំណត់តំបន់អភិវឌ្ឍន៍ជាអាទិភាព
- ប្លង់អភិវឌ្ឍន៍ទិសខាងជើង
- រៀបចំផែនការប្រើប្រាស់ដីកែបដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្មតំបន់ផ្សារដំណាក់ចង្អើរ ផ្សារកែប ផ្សារសេះស និងផ្សារក្តាម។

### ៥.២-ការផ្សព្វផ្សាយ

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកែប និងខេត្តកែប ត្រូវផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងកែបនេះ ដល់មន្ត្រីជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ តាមរយៈកិច្ចប្រជុំ សិក្ខាសាលា គេហទំព័រ ឬតាមបណ្តាញទំនាក់ទំនងសង្គម។ល។

### ៥.៣-ការអនុវត្តគម្រោងតាមវិស័យ

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍរួមមាន៖

#### ៥.៣.១-ការអភិវឌ្ឍក្រុង

- កំណត់ព្រំប្រទល់រដ្ឋបាលក្រុង សង្កាត់
- ដាក់លេខផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាល
- កែលម្អសោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្តាលក្រុង
- កសាងសមត្ថភាពធ្វើផែនការក្រុង
- រៀបចំអភិវឌ្ឍដីឡូត៍ដែលមិនទាន់បានប្រើប្រាស់ឱ្យធ្វើការអភិវឌ្ឍ និងប្រើប្រាស់ឱ្យចំទិសដៅ និងមុខងារ ប្រកបដោយចីរភាព
- រៀបចំនិងកំណត់រចនាបថអគារ ពណ៌អគារ និងរបង ឱ្យមានសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ ជាទីក្រុងទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ
- ការពារដីចំណីឆ្នេរសមុទ្រ ដោយកំណត់និងបោះបង្គោលព្រំប្រទល់ដីចំណីឆ្នេរសមុទ្រ ព្រែក ស្ទឹង អូរ បឹង និងបណ្តាញផ្លូវទឹកដែលភ្ជាប់ទៅនឹងសមុទ្រ
- សិក្សាទីតាំងនិងប្លង់កំពង់ផែទេសចរណ៍នៅតំបន់ដីគោក និងនៅតាមកោះ
- គ្រប់គ្រង អភិវឌ្ឍ និងអភិរក្សអគារព្រះរាជដំណាក់ព្រះរាជដំណាក់សម្តេចព្រះមហាក្សត្រិយានីស៊ីសុវត្ថិមុនីវង្សកុសុមនារីរ័ត្ន

- ថែរក្សា ការពារ កែលម្អ និងអភិវឌ្ឍឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ ផ្លូវស្របតាមបណ្តោយឆ្នេរសមុទ្រ ឱ្យមានអនាម័យ សោភ័ណភាព និងគុណភាពបរិស្ថានល្អ សម្រាប់មនុស្សទាំងអស់គ្នា និងសម្រាប់ជាប្រយោជន៍សាធារណៈ ស្របតាមចក្ខុវិស័យជារមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកដែលកំណត់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។ ដើម្បីសម្រេចការងារនេះ ម្ចាស់ដី ឬម្ចាស់អចលនទ្រព្យដែលនៅតាមបណ្តោយឆ្នេរសមុទ្រ មានកាតព្វកិច្ចចូលរួមក្នុងការថែរក្សា ការពារអនាម័យ និងអភិវឌ្ឍន៍កែលម្អឆ្នេរសមុទ្រដែលបន្ទុកចំណាយទាំងការអភិវឌ្ឍ និងការរៀបចំឆ្នេរសមុទ្រ សួនច្បារតាមបណ្តោយឆ្នេរសមុទ្រ ផ្លូវស្របតាមបណ្តោយឆ្នេរសមុទ្រ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងៗទៀត
- រៀបចំបទដ្ឋានរមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកដែលត្រូវកំណត់ដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- កោះចែកចេញជាកោះទំហំធំដែលមានទំហំចាប់ពី៥០០ ហិកតាឡើងទៅ កោះទំហំមធ្យមដែលមានទំហំចាប់ពី១០០ ទៅ៥០០ ហិកតា និងកោះទំហំតូចដែលមានទំហំក្រោម១០០ ហិកតា។ កោះទំហំមធ្យម ចែកចេញជាកោះទំហំមធ្យមប្រភេទទី១ កោះទំហំមធ្យមប្រភេទទី២ និងកោះទំហំមធ្យមប្រភេទទី៣
- កោះទំហំធំ ត្រូវកំណត់ទំហំឆ្នេរសមុទ្រយ៉ាងតិច៣០ ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីកោះ សម្រាប់ឆ្នេរជម្រាល និងយ៉ាងតិច២០ ម៉ែត្រ ចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីកោះ សម្រាប់ឆ្នេរចោត ព្រមទាំងត្រូវកំណត់ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រយ៉ាងតិច៥០ ម៉ែត្រ គិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីកោះ និងក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ
- ទំហំឆ្នេរសមុទ្រ និងប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រ នៃកោះទំហំមធ្យម និងកោះទំហំតូចនឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

### ៥.៣.២-ការអភិវឌ្ឍវិស័យទេសចរណ៍

- រៀបចំគម្រោងកែលម្អឆ្នេរកែប ចាប់ពីចំណុចសំណង់មិនរៀបរយមកដល់កំពង់ផែ និងចេញពីកំពង់ផែមកដល់រូបសំណាកស្រីស ដោយមានផ្លូវប្របមាត់សមុទ្រ សួនកម្សាន្ត សួនកុមារ សួនលម្ហែកាយ ទីលានសម្រាប់ប្រជាពលរដ្ឋមកពីបណ្តាខេត្តឆ្ងាយៗ ទីលានសម្រាប់បុណ្យសមុទ្រវិលជុំ ចំណតយានយន្ត បន្ទប់ទឹកអនាម័យសាធារណៈ

- កែលម្អឆ្នេរខ្សាច់កម្សាន្តឆ្នេរកែប តាមរយៈការចាក់បំពេញខ្សាច់ដែលមានពណ៌សក្បុស ពង្រីក និងបង្កើតបន្ថែមនូវឆ្នេរខ្សាច់សិប្បនិមិត្ត
- ពង្រីកឆ្នេរកម្សាន្តនៅចំណុចពយព្រះរាជដំណាក់ឱ្យមានចំណតរថយន្ត សួនច្បារលម្អកម្សាន្ត សួនកុមារ ផ្សាររាត្រី ទីលានសម្រាប់ប្រជាពលរដ្ឋមកពីបណ្តាខេត្តឆ្ងាយៗកម្សាន្ត និងសេវាបម្រើវិស័យទេសចរណ៍ផ្សេងៗទៀត
- កែលម្អផ្លូវព័ទ្ធពែនជុំវិញទំនប់ប៉ោហេង ដើម្បីបង្កើតបន្ថែមទៀតនូវតំបន់ទេសចរណ៍
- ត្រួតពិនិត្យគុណភាពចំណីអាហារ អនាម័យ ការស្នាក់នៅ ស្របតាមបទដ្ឋានអនាម័យ
- បណ្តុះបណ្តាលបុគ្គលិកដែលបម្រើសេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ច មគ្គុទេសក៍ទេសចរណ៍ និងអ្នកគ្រប់គ្រងសេវាកម្ម ឱ្យមានជំនាញវិជ្ជាជីវៈច្បាស់លាស់ នឹងឈានដល់កម្រិតស្តង់ដារជាតិ និងអន្តរជាតិ
- ផ្សព្វផ្សាយធនធានតំបន់ឆ្នេរសមុទ្រដ៏សម្បូរបែប និងប្រកបដោយភាពទាក់ទាញ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ គេហទំព័រតំបន់ទេសចរណ៍ បណ្តាញទំនាក់ទំនងសង្គម
- កែលម្អ និងរៀបចំផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្តល់សេវាកម្ម និងព័ត៌មានទេសចរណ៍
- បណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម ឆ្មាំសមុទ្រ និងដាក់ពង្រាយសន្តិសុខឱ្យបានគ្រប់គ្រាន់ ដើម្បីធានាសុវត្ថិភាពតាមរមណីយដ្ឋានទេសចរណ៍
- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងសាធារណៈខេត្តកែបលើវិស័យទេសចរណ៍
- អភិវឌ្ឍ និងលើកកម្ពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិ។

### ៥.៣.៣- ការដឹកជញ្ជូន

- កែលម្អ និងរៀបចំវិថី អនុវិថី ប្រព័ន្ធចរាចរណ៍ ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ ប្រព័ន្ធការពារសុវត្ថិភាព ផ្លូវសម្រាប់ដឹកជញ្ជូន ផ្លូវសម្រាប់ថ្មើរជើង គន្លងផ្លូវទោចក្រយាន ស្របតាមបទដ្ឋានបច្ចេកទេសអភិវឌ្ឍបៃតង ដោយធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ
- កែលម្អ និងពង្រីកផ្លូវជាតិលេខ៣៣អា វិថី អនុវិថី ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន ចិញ្ចើមផ្លូវ ភ្លើងបំភ្លឺ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម កំណត់ប្រភេទដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ សួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតង នៅក្នុងក្រុងកែបស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយសុខភាពល្អ សម្រាប់មនុស្សទាំងអស់គ្នា
- កសាងផ្លូវប្របមាត់សមុទ្រ តភ្ជាប់ជាមួយនឹងផ្លូវប្របមាត់សមុទ្រខេត្តកំពត

- កែលម្អ និងថែទាំបណ្ដាញផ្លូវដែលមានស្រាប់ក្នុងក្រុងអមដោយដើមរុក្ខជាតិផ្កា និងដើមឈើលម្អអមសងខាងផ្លូវ និងស្ទួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បរិក្ខាផ្លូវថ្នល់ ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រង និងបង្គោលភ្លើងភ្លឺចម្រុះពណ៌
- សាងសង់ស្ពានវិលង ស្ថិតនៅចំណុចរូបសំណាកស្រើស
- កែលម្អផ្លូវវង់តូចប្រវែង ៨ គីឡូម៉ែត្រក្នុងឧទ្យានជាតិ និងកសាងផ្លូវក្រវ៉ាត់ឧទ្យានជាតិ
- រៀបចំឱ្យមានរង្វង់មូលផ្លូវកែង ត្រង់ចំណុចរូបសំណាកស្ដេចកន និងរង្វង់មូលជាច្រើនទៀតនៃផ្លូវប្រឃមាត់សមុទ្រ
- កសាងកំពង់ផែទេសចរណ៍កម្រិតអន្តរជាតិត្រង់ចំណុចកំពង់ផែចាស់ និងជីកឃ្លងដើម្បីឱ្យទឹកសមុទ្រជ្រៅ ដើម្បីឱ្យនាវាទេសចរណ៍ចូលចតបាន
- កសាងចំណតទូកនេសាទ ដើម្បីគ្រប់គ្រងការនេសាទផង និងរក្សាសណ្ដាប់ធ្នាប់ សោភ័ណភាព របៀបរៀបរយទូកនេសាទតាមបណ្ដោយឆ្នេរសមុទ្រផង
- ការពារ និងថែរក្សាផ្លូវ ដីចំណីផ្លូវ និងដីស្ថានីយអយស្ម័យយាន
- ធ្វើទំនើបនីយកម្ម និងបើកឱ្យដំណើរការស្ថានីយអយស្ម័យយាន ដែលស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ដោយលើកទឹកចិត្តឱ្យមានការធ្វើដំណើរ និងដឹកជញ្ជូនតាមរថភ្លើង។

### ៥.៣.៤-ការពង្រឹងវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផល

- បណ្ដុះបណ្ដាលដល់ប្រជាកសិករអំពីផលប្រយោជន៍ និងវិធីសាស្ត្រក្នុងការប្រើប្រាស់ជីសរីរាង្គ
- អនុវត្តដំណើរការសហគមន៍មួយ ផលិតផលមួយ
- ពង្រឹង និងពង្រីកធនាគារក្ដាម
- ថែរក្សា និងការពារដីស្រែអំបិល ឱ្យមានចីរភាព
- ផ្សព្វផ្សាយផលិតផល និងពង្រីកផ្ទៃដីដាំដំណាំម្រេច ធុរេន និងសិប្បកម្មផលិតទឹកត្នោតឆ្អិន
- ការពារដីកសិកម្ម និងអភិវឌ្ឍវិស័យកសិកម្មបែបទំនើប
- ពង្រីកការកែច្នៃធនធានសមុទ្រ ដើម្បីលក់ជូនភ្ញៀវទេសចរ។

### ៥.៣.៥-ការគ្រប់គ្រងបរិស្ថាន

- ពង្រឹងសមត្ថភាពស្ថាប័ន
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- ប្រមូលកម្រែរួមពីសេវាកម្មសាធារណៈ។

### ៥.៣.៦-ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត

- កែលម្អ និងស្ដារអាងស្តុកទឹកទំនប់ប៉ោហេង សម្រាប់ផ្គត់ផ្គង់ជាប្រភពទឹកស្អាតក្នុងក្រុង
- រៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងដោយប្រើប្រាស់ប្រភពទឹកពីទំនប់ប៉ោហេង ឬភ្ជាប់ពីបណ្ដាញទឹកស្អាតរបស់ខេត្តកំពត

- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការផ្សេងៗ ក្នុងការការពារប្រភពផ្គត់ផ្គង់ទឹកបណ្តាលមកពីការអភិវឌ្ឍក្រុង។

**៥.៣.៧-ការគ្រប់គ្រងសំណល់រឹង**

- កសាងហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍទីលានទុកដាក់សំរាមអនាម័យដែលមានផ្ទៃដីទំហំសរុបប្រមាណ១៤ ហិកតា ស្ថិតនៅក្នុងភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ស្របតាមបទដ្ឋានបច្ចេកទេសបរិស្ថាន
- សហការជាមួយដៃគូរអភិវឌ្ឍន៍ ឬវិស័យឯកជន ដើម្បីប្រមូលកាកសំណល់រឹង
- អប់រំ និងផ្សព្វផ្សាយដល់ប្រជាជនអំពីគោលការណ៍គ្រប់គ្រងសំណល់រឹង តាមរយៈការកាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ
- តាមដាននិងវាយតម្លៃលើការប្រមូលនិងទុកដាក់សំរាមរបស់ដៃគូរអភិវឌ្ឍន៍ ឬវិស័យឯកជន
- តាមដានប្រសិទ្ធភាព គុណភាព និងតម្លៃនៃសេវាប្រមូលសំរាម
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនអំពីវិធានការគ្រប់គ្រងសំណល់រឹង។

**៥.៣.៨-ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ**

- កសាងអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅផ្សារក្តាម ឆ្នេរកែប ឆ្នេរថ្មី តំបន់ក្រោយផ្សារកែប ផ្សារដំណាក់ចង្អើរ និងទីប្រជុំជនផ្សារសេះស ឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលលូសាធារណៈ
- ណែនាំម្ចាស់សំណង់លំនៅឋាន សិប្បកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈឱ្យរៀបចំអាងប្រព្រឹត្តិកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបាននិរន្តរភាពតំបន់ទេសចរធម្មជាតិស្ងប់ស្ងាត់ និងស្នាក់នៅរយៈពេលយូរ។

**៥.៣.៩-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍**

- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- លើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ និងប្រើប្រាស់រថយន្តដើរដោយអាគុយ
- ពង្រីកតំបន់ទទួលបានការផ្គត់ផ្គង់ប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ឱ្យបានគ្របដណ្តប់ទូទាំងក្រុង
- តាមដានប្រសិទ្ធភាព គុណភាព និងតម្លៃនៃការផ្គត់ផ្គង់អគ្គិសនី និងទូរគមនាគមន៍។

### ៥.៣.១០-ការបង្ការទប់ស្កាត់គ្រោះមហន្តរាយ

- រៀបចំបណ្តាញលូរំដោះទឹក បន្តការដាំដើមឈើតាមបណ្តោយឆ្នេរសមុទ្រដែលធន់នឹងទឹកប្រៃ រៀបចំជើងទេរនៃឆ្នេរសមុទ្រ និងកសាងទំនប់ការពាររលកចំនួន៣ កន្លែង ដើម្បីការពាររលកធំៗ និងការហូរច្រោះឬភាពសឹករិចរិលនៃឆ្នេរសមុទ្រ
- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពកាយយកដីភ្នំ និងការកាប់ទន្ទ្រានព្រៃក្នុងឧទ្យានជាតិកែប ភ្នំ និងកសាងជញ្ជាំងទប់ភ្នំ ដើម្បីចៀសវាងកុំឱ្យរអិលបាក់ដីភ្នំ
- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពបូមយកដីនៅក្នុងបាតសមុទ្រដែលមិនសមស្របតាមបទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន
- ពង្រឹងយន្តការ និងមធ្យោបាយសម្រាប់បង្កាទប់ស្កាត់ និងប្រឆាំងភ្លើងឆេះព្រៃនៅក្នុងឧទ្យានជាតិ ភ្នំ និងនៅលើកោះ
- ពង្រឹងសមត្ថភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម។

## ៥.៤-ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពចែកចេញជា៣ ដំណាក់កាល គឺសម្រាប់ការអនុវត្តរយៈពេលខ្លី ឬគម្រោងអាទិភាព រយៈពេលមធ្យម និងរយៈពេលវែង ដូចខាងក្រោមៈ

### ៥.៤.១-ការអនុវត្តរយៈពេលខ្លី ឬគម្រោងអាទិភាព

- ផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងកែបនេះ ដល់ក្រុមជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ
- រៀបចំផែនការប្រើប្រាស់ដីក្រុងកែបដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្មតំបន់ផ្សារដំណាក់ចង្អើរ ផ្សារកែប ផ្សារសេះស និងផ្សារក្តាម
- ដាក់លេខផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាល
- កែលម្អសោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្តាលក្រុង
- រៀបចំអភិវឌ្ឍដីឡូត៍ដែលមិនទាន់បានប្រើប្រាស់ ឱ្យធ្វើការអភិវឌ្ឍ និងប្រើប្រាស់ឱ្យចំទិសដៅ និងមុខងារ ប្រកបដោយចីរភាព
- ផែនទីកំណត់កម្ពស់អគារក្នុងក្រុង ជាពិសេសនៅតាមបណ្តោយឆ្នេរសមុទ្រ និងនៅលើកោះ
- ផែនទីកំណត់ទីតាំងលម្អសាធារណៈ លម្អបៃតង ផ្លូវថ្នល់ ផ្លូវនិងស្ថានីយអេយស្ម័យយាន កំពង់ផែ ទំនប់ទឹក ប្រឡាយទឹក ដីចំណីឆ្នេរសមុទ្រ។ល។
- រៀបចំនិងកំណត់រចនាបថអគារ ពណ៌អគារ និងរបង ឱ្យមានសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ ជាទីក្រុងទេសចរណ៍ធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រ
- កែលម្អឆ្នេរខ្សាច់កម្សាន្តឆ្នេរកែប តាមរយៈការចាក់បំពេញខ្សាច់ដែលមានពណ៌សក្បុស ពង្រីក និងបង្កើតបន្ថែមនូវឆ្នេរខ្សាច់សិប្បនិម្មិត

- ត្រួតពិនិត្យគុណភាពចំណីអាហារ អនាម័យ ការស្នាក់នៅ ស្របតាមបទដ្ឋានអនាម័យ
- បណ្តុះបណ្តាលបុគ្គលិកដែលបម្រើសេវាកម្មទេសចរណ៍ និងបដិសណ្ឋារកិច្ច មគ្គុទេសក៍ទេសចរណ៍ និងអ្នកគ្រប់គ្រងសេវាកម្ម ឱ្យមានជំនាញវិជ្ជាជីវៈច្បាស់លាស់ នឹងឈានដល់កម្រិតស្តង់ដាជាតិ និងអន្តរជាតិ
- ផ្សព្វផ្សាយធនធានតំបន់ឆ្នេរសមុទ្រដ៏សម្បូរបែប និងប្រកបដោយភាពទាក់ទាញ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ គេហទំព័រតំបន់ទេសចរណ៍ បណ្តាញទំនាក់ទំនងសង្គម
- កែលម្អ និងរៀបចំផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្តល់សេវាកម្ម និងព័ត៌មានទេសចរណ៍
- បណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម ឆ្មាំសមុទ្រ និងដាក់ពង្រាយសន្តិសុខឱ្យបានគ្រប់គ្រាន់ ដើម្បីធានាសុវត្ថិភាពតាមរមណីយដ្ឋានទេសចរណ៍
- កែលម្អ និងរៀបចំវិថី អនុវិថី ប្រព័ន្ធចរាចរណ៍ ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ ប្រព័ន្ធការពារសុវត្ថិភាព ផ្លូវសម្រាប់ដឹកជញ្ជូន ផ្លូវសម្រាប់ថ្មើរជើង គន្លងផ្លូវទោចក្រយានតាមបទដ្ឋានបច្ចេកទេសអភិវឌ្ឍបៃតង ដោយធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ
- កែលម្អផ្លូវវង់តូចប្រវែង៨ គីឡូម៉ែត្រក្នុងឧទ្យានជាតិ និងកសាងផ្លូវក្រវ៉ាត់ឧទ្យានជាតិ
- កសាងចំណតទូកនេសាទ ដើម្បីគ្រប់គ្រងការនេសាទផង និងរក្សាសណ្តាប់ធ្នាប់ សោភ័ណភាព របៀបរៀបរយទូកនេសាទតាមបណ្តោយឆ្នេរសមុទ្រផង
- ធ្វើទំនើបនីយកម្ម និងបើកឱ្យដំណើរការស្ថានីយអយស្ម័យយាន ដែលស្ថិតនៅភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ ដោយលើកទឹកចិត្តឱ្យមានការធ្វើដំណើរ និងដឹកជញ្ជូន តាមរថភ្លើង
- ពង្រឹង និងពង្រីកធនាគារក្តាម
- ថែរក្សា និងការពារដីស្រែអំបិល ឱ្យមានចីរភាព
- ផ្សព្វផ្សាយផលិតផល និងពង្រីកផ្ទៃដីដាំដំណាំម្រេច ធុរេន និងសិប្បកម្មផលិតទឹកត្នោតឆ្អិន
- កែលម្អ និងស្តារអាងស្តុកទឹកទំនប់ប៉ោហេង សម្រាប់ផ្គត់ផ្គង់ជាប្រភពទឹកស្អាតក្នុងក្រុង
- រៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងដោយប្រើប្រាស់ប្រភពទឹកពីទំនប់ប៉ោហេង ឬភ្ជាប់ពីបណ្តាញទឹកស្អាតរបស់ខេត្តកំពត
- កសាងហេដ្ឋារចនាសម្ព័ន្ធ និងអភិវឌ្ឍទីលានទុកដាក់សំរាមអនាម័យដែលមានផ្ទៃដីទំហំសរុបប្រមាណ ១៤ ហិកតា ស្ថិតនៅក្នុងភូមិដំណាក់ចង្អើរ សង្កាត់ព្រៃធំ
- កសាងអាងប្រព្រឹត្តិកម្មទឹកកខ្វក់នៅផ្សារក្តាម
- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- រៀបចំបណ្តាញលូរំដោះទឹក បន្តដាំដើមឈើតាមបណ្តោយឆ្នេរសមុទ្រដែលធន់នឹងទឹកប្រៃ រៀបចំជើងទេរនៃឆ្នេរសមុទ្រ និងកសាងទំនប់ការពាររលកចំនួន៣ កន្លែង ដើម្បីការពាររលកធំៗ និងការហូរច្រោះឬភាពសឹករិចរិលនៃឆ្នេរសមុទ្រ